ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ **គាំទនាមប្រជារាស្ត្រខ្មែរ**

លេខ : ៩៦ **តុលាការកំពូល**

ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤

**សាលដីកា** បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៨ ខែ ធ្នូ

លេខ : ១០៣ ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- | លោក | វៀល មួន | ចៅក្រម |
| ៣- | លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៤- | លោក | ស៊ិន ឌីម | ចៅក្រម |
| ៥- | លោក | ប៉ែន សារឿន | ចៅក្រម |
| ៦- | លោក | គង់ ភិរុន | ចៅក្រម |
| ៧- | លោក | យស់ សួខឿន | ចៅក្រម |
| ៨- | លោក | សោម សិរីវឌ្ឍ | ចៅក្រម |
| ៩- | លោក | ម៉ុង មុន្នីចរិយា | ចៅក្រម-របាយការណ៍ |

ក្រឡាបញ្ជី

លោក **សាន សុផាត**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ពិរុទ្ធ*** : ជួញគ្រឿងញៀន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១-ជនជាប់ចោទឈ្មោះឈុន ចាន់ថុង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ របររកស៊ីយោធា ទីលំនៅមុនថ្ងៃចាប់ខ្លួន នៅក្រុមទី៨ មណ្ឌល៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះឈុន ចាន់ថុន "រ" ម្តាយឈ្មោះសួង សារី "រ" ប្រពន្ធឈ្មោះធូ សុម៉ាលី មានកូនពីរនាក់ ។ ក្នុងឃុំ ។

២-ជនជាប់ចោទឈ្មោះឈុំ ធឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ីរត់ម៉ូតូឌុប ទីលំនៅមុនពេលចាប់ខ្លួន មណ្ឌល០១ សង្កាត់០៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះដុះ ឈុំ ម្តាយឈ្មោះសួង សារី "រ" ប្រពន្ធឈ្មោះធូ សុម៉ាលី មានកូន០២នាក់ ។

-មានមេធាវី : លោក កែ ចំរើន

៣-ជនជាប់ចោទឈ្មោះសៀម វាសនា ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាលប៉ុស្តិ៍នាងកុក ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិនាងកុក ឃុំបាក់ខ្លង ស្រុកកោះកុង ខេត្តកោះកុង ។ ឪពុកឈ្មោះសៀម មាន (រ) ម្តាយឈ្មោះឡុង គួ (ស) ប្រពន្ធឈ្មោះតេង វ៉ា មានកូន០២នាក់ ។ ក្នុងឃុំ ។

៤-ជនជាប់ចោទឈ្មោះឈុន ចាន់ដារ៉ា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មករនេសាទ ទីលំនៅមុនថ្ងៃចាប់ខ្លួន នៅក្រុម២៧ មណ្ឌល៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះម៉ិច ចាំ "ស" ម្តាយឈ្មោះ ប៊ូ ហ៊ុច "ស" ប្រពន្ធឈ្មោះតេង មួយ មានកូន០១នាក់ ។

៥-ជនជាប់ចោទឈ្មោះអាត អុន ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ត្រី ទីលំនៅមុនពេលចាប់ខ្លួននៅភូមិនាងកុក ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។ ឪពុកឈ្មោះអាត អិត ម្តាយឈ្មោះកាំ ប៉ា ប្តីឈ្មោះយិន លីន មានកូនបីនាក់ ។

-តាមកំណត់ហេតុចាប់ជាក់ស្តែងថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន បានចាប់ជនល្មើសចំនួន២នាក់ គឺឈ្មោះឈុំ ធឿន និង ឈុន ចាន់ថុង ដោយនៅពេលចាប់ជនល្មើសនេះ បានដកហូតវត្ថុតាងម្សៅហេរ៉ូអ៊ីន១,៤គីឡូ និងតាមកំណត់ហេតុស្តីពីការធ្វើតេស្តលើម្សៅដែលបានរឹបអូសពីជនល្មើសឈ្មោះឈុំ ធឿន ជាមួយប្រតិករ៦ មានប្រតិកម្មវិជ្ជមានជាហេរ៉ូអ៊ីន និង បានយកហេរ៉ូអ៊ីន ដាក់បញ្ចូលក្នុងស្បោងផ្លាស្ទិកដែលមានលេខសំគាល់៥K២៤៧៩៥២ និង អ៊ុតជិត ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញសំរេច : ចោទប្រកាន់ឈ្មោះសៀម វាសនា , ឈុន ចាន់ថុង , ឈុំ ធឿន , ឈុន ចាន់ ដារ៉ា និង អាត អុន ពីបទជួយដូរគ្រឿងញៀន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង បង្គប់បណ្តឹងអាជ្ញាលើគួកន ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-បង្គប់បណ្តឹងអាជ្ញាលើឈ្មោះទិត អួន និង ឈ្មោះវៀម ពីបទ ជួញគ្រឿងញៀននៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ ព្រោះគ្មានសាវតាជាតិ ។

២-ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះសៀម វាសនា ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ឈ្មោះឈុន ចាន់ថុង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ,ឈ្មោះឈុំ ធឿន ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ឈ្មោះឈុន ចាន់ដារ៉ា ភេទប្រុស ជាតិខ្មែរ និង ឈ្មោះអាត អុន ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ ក្នុងម្នាក់១ ចំនួន១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី១៣ ខែតុលា ឆ្នាំ១៩៩៧ ពីបទជួញគ្រឿងញៀននៅក្រុងភ្នំពេញ កាលពីថ្ងៃ ទី០៧ ខែតុលា ឆ្នាំ១៩៩៧ តាមមាត្រាទី៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-រឹបអូសម្សៅគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនទម្ងន់១.៤០០ក្រាម ដែលឃុំបេជិត ដាក់ ថងលេខ៥K២៤៧៩៥២ ដើម្បីបំផ្លាញចោល ។

៤-ប្រគល់នាឡិកាដៃម៉ាកអូប៉េ ពណ៌លឿងលេខ៨៩៣២ មួយគ្រឿង ប័ណ្ណសំគាល់ សមាជិកលេខសន០១០០៧ យ ឆ ប័ណ្ណអាវុធវែងមួយសន្លឹកលេខចូលបញ្ជី ២១៦-៩៧ ប័ណ្ណសំគាល់ខ្លួន មួយសន្លឹកលេខ អឹម០៤-៩៧ក-២ អោយទៅឈ្មោះឈុន ចាន់ថុង វិញ ។

ប្រគល់ត្បូងពណ៌ក្រហមចំនួន៣៦គ្រាប់ ខ្សែកមួយខ្សែប្រវែង៦តឹក ជាលោហពណ៌ លឿង បណ្តោងរូបព្រះចំនួនពីរ ស្រោបដោយលោហពណ៌លឿង ខ្សែដៃមួយខ្សែមានដាំត្បូងពណ៌ក្រហម ចំនួន១៥គ្រាប់ អោយទៅឈ្មោះអាត អុន ។

ប្រគល់លិខិតសំគាល់ខ្លួនលេខក ០០២៦៥៩ អត្តសញ្ញាណប័ណ្ណលេខ ០៣០៩៦៥កក ៤ អោយឈ្មោះសៀម វាសនា ។

៥-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទសំរេចបើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៧"ក" ចុះថ្ងៃទី១០ ខែមេសា ឆាំ១៩៩៨ របស់ឈ្មោះអាត អុន ឈុន ចាន់ដារ៉ា , ឈុន ចាន់ថុង ,សៀម វាសនា , ឈុំ ធឿន ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ២៧"ក" ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ របស់ជនជាប់ ចោទ អាត អុន , ឈុន ចាន់ដារ៉ា , ឈុំ ធឿន , ឈុន ចាន់ថុង និង សៀម វាសនា ទុកជាត្រឹមត្រូវតាម ទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះអង្គច្បាប់ ។

២-តម្កល់សាលក្រមលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុង ភ្នំពេញ ទុកជាបានការតទៅ លើកលែងតែចំណុចទី១ នៃសេចក្តីសំរេច ដែលត្រូវបដិសេធចោលជាអសារ-បង់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហាឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះអាត អុន ឈុន ចាន់ដារ៉ា , ឈុន ចាន់ថុង , សៀម វាសនា និង ឈុំ ធឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល គ្រាន់តែកែប្រែរយៈពេលនៃការផ្ដន្ទាទោសលើឈ្មោះអាត អុន ឈុំ ធឿន និង ឈុន ចាន់ថុង ក្នុងចំណុចទី២ នៃសេចក្ដីសំរេចពី១០ឆ្នាំ មក៧ឆ្នាំ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ឈុំ ធឿន , ឈុន ចាន់ថុង ,ឈុន ចាន់ដារ៉ា , សៀម វាសនា និង មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះអាត អុន បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ៦៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : តុលាការក្រុងភ្នំពេញក៏ដូចសាលាឧទ្ធរណ៍ដែលសំរេចបង្អង់បណ្ដឹងអាជ្ញាលើឈ្មោះទិត្យ អួន និង វៀម ដោយហេតុថាគ្មានសាវតាជាតិច្បាស់លាស់ នោះជាការភ័ន្តច្រឡំ ពីព្រោះថា តាមចម្លើយជនជាប់ចោទឈ្មោះសៀម វាសនា និង ឈុន ចាន់ដារ៉ា នៅចំពោះមុខនគរបាលប្រឆាំងគ្រឿងញៀន ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧ ថា អា វៀម មានឈ្មោះពិត ទិន វៀម ធ្វើនគរបាល មានទីលំនៅ១ត្រង់ដៃអូរប៉ែនាងកុក ឈ្មោះអួន មានមុខរបរជានគរបាលប៉ុស្ដិ៍នាងកុក ។

+ការដែលសាលាឧទ្ធរណ៍សំរេចកែប្រែរយៈពេលនៃការផ្ដន្ទាទោសលើឈ្មោះ អាត អុន ឈុំ ធឿន និង ឈុន ចាន់ថុង ពី១០ឆ្នាំ មក៧ឆ្នាំ ដោយអាងហេតុថា នាពេលសវនាការនៅសាលាឧទ្ធរណ៍ ជនជាប់ចោទបានឆ្លើយទទួលស្គាល់កំហុសរបស់ខ្លួន ហើយមានស្មារតីភ្ញាក់រលឹកកែប្រែខ្លួនអោយក្លាយជាមនុស្សត្រឹមត្រូវវិញ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា សំអាងហេតុនេះពុំមែនជាស្ថានសំរាលដែលសាលាឧទ្ធរណ៍លើកយកមកពិចារណាក្នុងពេលនេះឡើយ ។

+បដិសេធសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលបានសំរេច :

១-ទទួលបណ្ដឹងសាទុក្ខលេខ៦៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ របស់អគ្គព្រះរាជ-អាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលបណ្ដឹងសាទុក្ខលេខ៦៥ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ របស់លោកសាម-ចាន់ឌីណា បណ្ដឹងសាទុក្ខលេខ៦៧ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះឈុំ ធឿន និង បណ្ដឹងសាទុក្ខលេខ៧២ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះឈុន ចាន់ដារ៉ា និង ឈ្មោះឈុន ចាន់ថុង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចផ្តន្ទាទោសឈ្មោះសៀម វ៉ាសនា ដែលត្រូវតម្កល់ទុកជាបានការ ។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៩០ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០២ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

១-ទទួលជំនុំជំរះជាថ្មីឡើងវិញ តាមអំណាចសាលដីការបស់តុលាការកំពូល ។

២-តម្កល់សាលក្រមលេខ២១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការតទៅ លើកលែងតែចំណុចទី១ នៃសេចក្តីសំរេច ត្រូវបដិសេធចោលជាអសារបង់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៩"ង" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ២៣៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆាំ២០០២ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០២ របស់តុលាការកំពូល ។

២-ផ្តន្ទាទោសលើឈ្មោះ

-ឈុន ចាន់ថុង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ

-ឈុំ ធឿន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ

-ឈុន ចាន់ដារ៉ា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ

-អាត អុន ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន១០ឆ្នាំ គិតពីថៃឃុំខ្លួនថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ ពីបទជួញដូរគ្រឿងញៀន ប្រព្រឹត្តកាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ នៅក្រុងភ្នំពេញ តាមមាត្រាទី៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ឈុន ចាន់ថុង , ឈុំ ធឿន , ឈុន ចាន់ដារា ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខឈ្មោះ អាត អុន ។ សំរេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះឈុន ចាន់ថុង និង ឈ្មោះឈុំ ធឿន ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៥"ង"ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះឈុំ ធឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះឈុន ចាន់ដារា (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះត្រឹមត្រូវ ប៉ុន្តែសាលាឧទ្ធរណ៍មិនបានសំរេចបង្គង់បណ្តឹងអាជ្ញាលើឈ្មោះអូន និង ឈ្មោះរៀម ដោយឡែកវត្ថុតាងសាលាឧទ្ធរណ៍ពុំបានសំរេចរឹបអូសចំណាយចោលទេ។ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សំរេច ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះឈុន ចាន់ថុង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : សូមតុលាការកំពូលសំរេចតាមសាលដីកាលើកទី១ របស់សាលាឧទ្ធរណ៍ ខ្ញុំព្រមទទួលទោស៧ឆ្នាំ ខ្ញុំភ្ញាក់រលឹកកែប្រែខ្លួន សូមតុលាការបន្ធូរបន្ថយទោសដល់ខ្ញុំបាទផង ណាមួយខ្ញុំបាទជាប់ពន្ធនាគារ៨ឆ្នាំហើយ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះឈុំ ធឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្ញុំឯកភាពតាមចំលើយរបស់ឈ្មោះឈុន ចាន់ថុង សូមតុលាការបន្ធូរបន្ថយទោសខ្ញុំផង ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែ ចំរើន ជាមេធាវីការពារជនជាប់ចោទឈ្មោះឈុំ ធឿន និង ឈុន ចាន់ថុង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : កូនក្តីខ្ញុំបាទចាញ់បោកគេ ល្ងិតល្ងង់មិនយល់ដឹងពីច្បាប់មានប្រពន្ធ មានកូន មានឪពុក ម្តាយចាស់ជរា ហើយបានទទួលសារភាព និង មានសំបុត្របញ្ជាក់ពីពន្ធនាគារ ។ សូមតុលាការបន្ធូរបន្ថយទោសផង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : គ្មានយោបល់បន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ឈុន ចាន់ថុង និង ឈ្មោះឈុំ ធឿន និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-*យល់ឃើញថា* : បណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ របស់ជនជាប់ចោទឈ្មោះឈុន ចាន់ថុង និង ឈ្មោះឈុំ ធឿន ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និង មាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-*យល់ឃើញថា* : ជនជាប់ចោទនៅក្នុងរឿងនេះ ដែលក្នុងនោះក៏មានឈ្មោះឈុំ ធឿន និងឈ្មោះឈុន ចាន់ថុង ដែរ បានសារភាពពីអំពើរបស់ខ្លួននៅចំពោះមុខការស៊ើសួរ និង ចំពោះមុខសវនាការកន្លងមក ដែលមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងវត្ថុតាង គឺម្សៅហេរ៉ូអ៊ីនចំនួន១.៤០០ក្រាម ដែលត្រូវបានរឹបអូសជាក់ស្តែងពីការកាន់កាប់របស់ក្រុមជនជាប់ចោទនៅថ្ងៃចាប់ខ្លួន ។

-*យល់ឃើញថា* : ការដែលសាលាឧទ្ធរណ៍សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារដល់ជនជាប់ចោទឈ្មោះឈុំ ធឿន និង ឈ្មោះឈុន ចាន់ថុង ម្នាក់១ចំនួន១០ឆ្នាំ នោះជាការត្រឹមត្រូវតាមការកំណត់នៃមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនហើយ។ ការដែលជនជាប់ចោទឈ្មោះឈុន ចាន់ថុង លើកឡើងពីការកែប្រែខ្លួន និង បានផ្តល់សំអាងជាលិខិតបញ្ជាក់របស់ប្រធានពន្ធនាគារដែលមានន័យថាឈ្មោះនេះបានកែប្រែខ្លួន និង មានការគោរពវិន័យពន្ធនាគានោះ គឺពុំមែនជាមូលហេតុ ឬ ជាស្ថានភាពដែលអាចធ្វើការពិចារណាពីស្ថានបន្ធូបន្ថយទោសបាននោះឡើយ ។

-*យល់ឃើញថា* : ក្នុងការសំរេចសេចក្តីជាថ្មីសាលាឧទ្ធរណ៍ពុំបានសំរេចអំពីការបង្គង់បណ្តឹងអាជ្ញាលើឈ្មោះទិន វៀម និង ឈ្មោះអួន ដូចការចង្អុលបង្ហាញរបស់តុលាការកំពូលទេ ដែលគប្បីតុលាការកំពូលពិចារណា និង សំរេចបន្ថែម ។

-*យល់ឃើញថា* : តាមចម្លើយរបស់ឈ្មោះឈុន ចាន់ដារ៉ា និង ឈ្មោះសៀម វ៉ាសនា នៅចំពោះមុខនគរបាលយុត្តិធម៌កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧ ថា ឈ្មោះវៀម មានឈ្មោះពិត គឺ ទិន វៀម មានមុខរបរធ្វើនគរបាល និង មានទីលំនៅត្រង់ដែអូច័រនាងកុក រីឯឈ្មោះអួន គឺ ទិត្យ អួន មានមុខរបរជានគរបាលនៅប៉ុស្តិ៍នាងកុក ហើយម្យ៉ាងទៀតបទល្មើសដែលត្រូវចោទប្រកាន់ នៅមិនទាន់ផុតអាជ្ញា-យុកាលនៃបទល្មើសនៅឡើយទេ ដែលគប្បីតុលាការក្រុងភ្នំពេញលើកយកករណីជនពីររូបនេះមកចាត់ការបន្ត ។

-*យល់ឃើញថា* : នៅក្នុងរឿងនេះមានវត្ថុតាង ដែលត្រូវបានរឹបអូសមានដូចជា ម្សៅហេរ៉ូអ៊ីនចំនួន១.៤០០ក្រាម និង វត្ថុប្រើប្រាស់របស់ជនជាប់ចោទ តែសាលាឧទ្ធរណ៍មិនទាន់បាន សម្រេចពីវាសនានៃវត្ថុតាងទាំងនោះឡើយ ។

-*យល់ឃើញថា* : ការដែលជនជាប់ចោទទាំងពីរនាក់ ក៏ដូចមេធាវីរបស់ឈ្មោះទាំងពីរនាក់នេះដែរ ដែលសុំអោយតុលាការកំពូលបន្ធូរបន្ថយទោសនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះទណ្ឌកម្មដែលតុលាការថ្នាក់ក្រោមកំណត់នេះ មានកំរិតតែអប្បរិមានៃទោសហើយ ។

-*យល់ឃើញថា* : សាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ តែមានចំណុចខ្វះចន្លោះ ដែលត្រូវសម្រេចបន្ថែម ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះឈុន ចាន់ថុង និង ឈុំ ធឿន

១-ទទួលបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ របស់ជនជាប់ចោទឈ្មោះឈុន ចាន់ថុង និងឈ្មោះឈុំ ធឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២១៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការ ដោយសំរេចបន្ថែម ។

៣-ក/-បង្គាប់អោយតុលាការក្រុងភ្នំពេញចាត់ការលើឈ្មោះទិន វៀម និង ឈ្មោះទិត អួនឡើងវិញ តាមដីកាលេខ១៤៩៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៧ និង លេខ១៦១៤ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ របស់អយ្យការក្រុងភ្នំពេញ ។

ខ/-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការបន្តតាមសមត្ថកិច្ច ។

៤-វត្ថុតាងមាន :

ក/-មៀវហេរ៉ូអ៊ីនទម្ងន់១.៤០០ក្រាម ដាក់ក្នុងថង់លេខ5K247952 ត្រូវរឹបអូស និង បំផ្លាញចោល ។

ខ/-នាឡិកាដៃម៉ាក OP ពណ៌លឿងលេខ 8932E ចំនួន០១គ្រឿង ប័ណ្ណសំគាល់សមាជិកលេខសន០១០០៧ យ ឆ . ប័ណ្ណអាវុធវែងលេខចុះបញ្ជី ២៦៦-៩៧ .ប័ណ្ណសំគាល់ខ្លួនលេខ M04/97 ក២ ត្រូវប្រគល់ឱ្យទៅឈ្មោះឈុន ចាន់ថុង វិញ ។

-ត្បូងពណ៌ក្រហមចំនួន៣៦គ្រាប់ . ខ្សែករមួយខ្សែប្រវែង០.៦ម ជាលោហៈធាតុពណ៌លឿង ខ្សែដៃមួយខ្សែមានដាំត្បូងពណ៌ក្រហមចំនួន១៥គ្រាប់ ត្រូវប្រគល់ឱ្យទៅឈ្មោះអាត អុន វិញ ។

-លិខិតសំគាល់ខ្លួនលេខក០០២៦៩៩ . អត្តសញ្ញាណប័ណ្ណលេខ០៣០៩៦៥ ក-ក៤ ត្រូវប្រគល់ឱ្យឈ្មោះសៀម វាសនា វិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥ ។